# លក្ខខណ្ឌការងារសម្រាប់ការជ្រើសរើស
# ក្រុមហ៊ុនផ្តល់សេវាការអន្តេតអភិបាលកិច្ចក្នុងក្របខណ្ឌនៃកម្មវិធីជាតិសម្រាប់ការ
# អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២

## ១. សេចក្តីផ្តើម៖

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) គឺជាគណៈកម្មាធិការអន្តរក្រសួងដែលមានតួនាទីជាសេនាធិការឱ្យរាជរដ្ឋាភិបាលក្នុងការដឹកនាំ សម្របសម្រួល និងគ្រប់គ្រងការរៀបចំ និងការអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ឬហៅម្យ៉ាងទៀតថា កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

លេខាធិការដ្ឋាននៃ គ.ជ.អ.ប. គឺជាសេនាធិការឱ្យ គ.ជ.អ.ប. ក្នុងការសម្របសម្រួល ការគ្រប់គ្រង ការរៀបចំ និងការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលជាផែនការរយៈពេលវែងសម្រាប់អនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងច្បាប់រៀបចំអង្គការ រួមមាន ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ តាមដំណាក់កាលនីមួយៗ។

ក្នុងក្របខណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ រហូតមកដល់ពេលនេះ គ.ជ.អ.ប. បាន និងកំពុងដឹកនាំ សម្របសម្រួលការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល១០ឆ្នាំដំណាក់កាលទី២ (កជទី២) បន្ទាប់ពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី១ ត្រូវបានអនុវត្តបញ្ចប់នៅចុងឆ្នាំ២០២០។

**កជទី២**ដែលត្រូវអនុវត្តរយៈពេល១០ឆ្នាំពីឆ្នាំ២០២១ដល់ឆ្នាំ២០៣០ មានគោលបំណង "**លើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ប្រកបដោយបរិយាប័ន្ន សមធម៌សង្គម និងយុត្តិធម៌ តាមរយៈការធ្វើទំនើបកម្មប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ និងការកែលម្អដំណើរការផ្តល់សេវា និងគុណភាពសេវា ដើម្បីចូលរួមចំណែកលុបបំបាត់ភាពក្រីក្រ លើកកម្ពស់គុណភាពជីវិតរបស់ប្រជាជនឱ្យកាន់តែល្អប្រសើរឡើង**"។

ដើម្បីឆ្ពោះទៅសម្រេចបានគោលបំណងនេះ **កជទី២**បានកំណត់គោលដៅជាក់លាក់មួយ គឺ "**រចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានលក្ខណៈទំនើប មានស្វ័យភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមានសិទ្ធិអំណាចសមស្រប និងសមត្ថភាពគ្រប់គ្រាន់សម្រាប់អនុវត្តមុខងារទាំងឡាយក្រោមការត្រួតពិនិត្យពីក្រុមប្រឹក្សា ដើម្បីឆ្ពោះទៅដល់ការពង្រឹងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ**"។

ក្នុងក្របខណ្ឌនៃការវាយតម្លៃគោលបំណង និងគោលដៅខាងលើនេះ **កជទី២**បានតម្រូវឱ្យកំណត់សន្ទស្សន៍ជាយុទ្ធសាស្ត្រចំនួន២សំខាន់គឺ៖

១. **សន្ទស្សន៍ផ្នែកអភិបាលកិច្ច** ដែលជាបណ្តុំសូចនាករសម្រាប់ជាមូលដ្ឋានក្នុងការវាស់វែងនូវកម្រិតនៃការសម្រេចបានគោលបំណងនៃ**កជទី២**

២. **សន្ទស្សន៍ផ្នែកការផ្តល់សេវា** ដែលជាបណ្តុំសូចនាករសម្រាប់ជាមូលដ្ឋានក្នុងការវាស់វែងកម្រិតនៃការសម្រេចបានគោលដៅនៃ**កជទី២**។

ការកំណត់សន្ទស្សន៍ជាយុទ្ធសាស្ត្រខាងលើឱ្យបានត្រឹមត្រូវ និងច្បាស់លាស់ គឺជាកត្តាដ៏មានសារៈសំខាន់ក្នុងការវាស់វែងកម្រិតភាពជោគជ័យនៃការអនុវត្ត **កជទី២**។ ការកំណត់សន្ទស្សន៍ជាយុទ្ធសាស្ត្រនេះត្រូវធ្វើឡើងតាម**ការធ្វើអង្កេតអភិបាលកិច្ច** ដែលជាការសិក្សាតាមដានអំពីការផ្លាស់ប្តូរសន្ទស្សន៍គន្លឹះៗមួយចំនួនពាក់ព័ន្ធនឹងអភិបាលកិច្ចដូចជា ការផ្តល់សេវា ការឆ្លើយតប ការចូលរួមរបស់ប្រជាពលរដ្ឋ តម្លាភាព និងគណនេយ្យភាព ដោយផ្អែកជាសំខាន់ទៅលើទស្សនៈយល់ឃើញរបស់ប្រជាពលរដ្ឋ ក្រុមប្រឹក្សា និងគណៈអភិបាលរដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្នុងន័យនេះ ដោយមានការគាំទ្រពីគម្រោង "**ការពង្រឹងតម្លាភាព និងគណនេយ្យភាពក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ**" របស់កម្មវិធីអង្គការអភិវឌ្ឍសហប្រជាជាតិ(UNDP) ដែលទទួលបានហិរញ្ញប្បទានពីរាជរដ្ឋាភិបាលជប៉ុន លេខាធិការដ្ឋាន គ.ជ.អ.ប. គ្រោងនឹងរៀបចំការធ្វើអង្កេតអភិបាលកិច្ចមួយដើម្បីកំណត់សន្ទស្សន៍ជាយុទ្ធសាស្ត្រទាំងនេះ ដើម្បីធ្វើជា**ទិន្នន័យដើមគ្រា**សម្រាប់វាស់វែងកម្រិតនៃភាពជោគជ័យក្នុងការអនុវត្ត**កជទី២**។

ការធ្វើអង្កេតអភិបាលកិច្ចនេះត្រូវអនុវត្តដោយក្រុមហ៊ុនផ្តល់សេវាទីប្រឹក្សា (consulting firm) ឬស្ថាប័នសិក្សាស្រាវជ្រាវដែលត្រូវជ្រើសរើស និងចុះកិច្ចសន្យាការងារជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. តាមគោលការណ៍ បែបបទ និងនីតិវិធីជាធរមាន។

## ២. គោលបំណង

ការធ្វើអង្កេតអភិបាលកិច្ចនេះ មានគោលបំណងបង្កើតសន្ទស្សន៍ជាយុទ្ធសាស្ត្រសំខាន់ៗចំនួន២ គឺ សន្ទស្សន៍ផ្នែកអភិបាលកិច្ច និងសន្ទស្សន៍ផ្នែកការផ្តល់សេវា ដើម្បីធ្វើជាទិន្នន័យដើមគ្រា ដោយផ្តោតទៅលើសូចនាករសំខាន់ៗពាក់ព័ន្ធនឹង (១) ការផ្តល់សេវាសាធារណៈ (២) ការឆ្លើយតប (៣) ការចូលរួមរបស់ប្រជាពលរដ្ឋ (៤) តម្លាភាព និង(៥)គណនេយ្យភាព។

## ៣. ទំហំការងារ Scope of work

ផ្អែកលើគោលបំណងខាងលើ ក្រុមហ៊ុនផ្តល់សេវាទីប្រឹក្សា ឬស្ថាប័នសិក្សាស្រាវជ្រាវដែលចុះកិច្ចសន្យាការងារជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវបំពេញកិច្ចការសំខាន់ៗរួមមានដូចជា ការកំណត់អំពីវិធីសាស្ត្រ ឧបករណ៍ ការរៀបចំបញ្ជីសំណួរ ការប្រមូលទិន្នន័យ ការបញ្ចូលទិន្នន័យ ការរៀបចំវិភាគទិន្នន័យបង្កើតជាសន្ទស្សន៍អភិបាលកិច្ច និងសន្ទស្សន៍ការផ្តល់សេវាដើម្បីរៀបចំជាទិន្នន័យដើមគ្រាសម្រាប់វាស់វែងកម្រិតនៃភាពជោគជ័យនៃការសម្រេចបានតាមគោលដៅ និងគោលបំណងនៃ**កជទី២**។

ការរៀបចំកិច្ចការទាំងនេះត្រូវផ្តោតលើការប្រមូលព័ត៌មាន និងទិន្នន័យដែលពាក់ព័ន្ធនឹង៖

(១) ប្រព័ន្ធអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមមានដូចជា រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង សិទ្ធិអំណាច មុខងារ ធនធាន ការទទួលខុសត្រូវ និងនីតិវិធីបំពេញការងាររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់

(២) ការផ្តល់សេវាសាធារណៈរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ រួមមានដូចជា ការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយ ការអនុវត្តមុខងារជាកាតព្វកិច្ច (មុខងារផ្តល់សេវាអប់រំ យុវជន និងកីឡា...) និងការអនុវត្តមុខងារជាជម្រើសនានា (ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ការអនុវត្តគម្រោងផ្តល់សេវាសង្គមនានា)។

ការរៀបចំបញ្ជីសំណួរសម្រាប់ប្រមូលទិន្នន័យ និងព័ត៌មានទាំងនេះត្រូវបែងចែកពីរប្រភេទ៖

(១) បញ្ជីសំណួរសម្រាប់ប្រមូលព័ត៌មានជាលក្ខណៈបុគ្គល (ការសម្ភាសន៍ជាមួយប្រជាពលរដ្ឋ) អំពីការយល់ឃើញ និងការពេញចិត្តលើការបំពេញការងារ ការគ្រប់គ្រង ការទទួលខុសត្រូវ ការធ្វើគណនេយ្យភាព តម្លាភាព ការលើកទឹកចិត្តឱ្យមានការចូលរួមពីប្រជាពលរដ្ឋ និងការផ្តល់សេវាសាធារណៈក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់នីមួយៗ និង

(២) បញ្ជីសំណួរសម្រាប់ប្រមូលព័ត៌មានតាមរយៈការសម្ភាសន៍ជាមួយសមាជិកក្រុមប្រឹក្សា និង គណៈអភិបាលក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់។

ក្រុមហ៊ុនផ្តល់សេវាទីប្រឹក្សា ឬស្ថាប័នសិក្សាស្រាវជ្រាវត្រូវបំពេញកិច្ចការទាំងនេះ ដោយមានការសម្របសម្រួលពីលេខាធិការដ្ឋាន គ.ជ.អ.ប. ព្រមទាំងត្រូវមានការពិនិត្យ ពិភាក្សាពិគ្រោះយោបល់ជាមួយក្រុមការងារបច្ចេកទេសពិគ្រោះយោបល់នៃគម្រោង "**ការពង្រឹងតម្លាភាព និងគណនេយ្យភាពក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ**"

## ៤. ការកំណត់សំណាកសម្រាប់ការអង្កេតអភិបាលកិច្ច

ការអង្កេតអភិបាលកិច្ចនេះត្រូវធ្វើនៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ក្នុងរាជធានីភ្នំពេញ ខេត្តចំនួន២៤ ក្នុងនោះ រដ្ឋបាលក្រុង ស្រុក ខណ្ឌ**ចំនួន៩៦** រដ្ឋបាលឃុំ សង្កាត់ចំនួន**១៩២** និងភូមិចំនួន**៣៨៤**។ អ្នកផ្តល់ព័ត៌មានដែលត្រូវជួបសម្ភាសន៍ត្រូវមានចំនួនសរុបយ៉ាងតិច**៣.៨៥៩រូប** រួមមាន៖ ប្រជាពលរដ្ឋចំនួនយ៉ាងតិច**១.១៨៩រូប** ក្នុងនោះ៥០%ជាស្ត្រី សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ចំនួន**៨៥៦រូប** (ត្រូវផ្តល់អាទិភាពដល់សមាជិកក្រុមប្រឹក្សាជាស្ត្រី) សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន **១.០១៤រូប** (ត្រូវផ្តល់អាទិភាពដល់សមាជិកក្រុមប្រឹក្សាជាស្ត្រី)និងមន្ត្រីផ្តល់សេវាសាធារណៈរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ចំនួន**៨០០រូប** (ផ្តល់អាទិភាពដល់មន្ត្រីជាស្ត្រី)។

ការកំណត់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់គោលដៅសម្រាប់ការធ្វើអង្កេតអភិបាលកិច្ចនេះត្រូវជ្រើសរើសឱ្យមានភាពតំណាងឱ្យតំបន់ទីក្រុងធំៗ តំបន់ទីប្រជុំជន តំបន់ជនបទ តំបន់ភ្នំ តំបន់ទន្លេសាប តំបន់សមុទ្រ។ អ្នកផ្តល់ព័ត៌មានដែលត្រូវជួបសម្ភាសន៍ប្រមូលព័ត៌មានសម្រាប់ការធ្វើអង្កេតអភិបាលកិច្ចនេះត្រូវអនុវត្តតាមវិធីសាស្ត្រការជ្រើសរើសដោយចៃដន្យ។

ក្រុមហ៊ុនផ្តល់សេវាទីប្រឹក្សា ឬស្ថាប័នសិក្សាស្រាវជ្រាវត្រូវរៀបចំវិធីសាស្ត្រជ្រើសរើសសំណាក

សម្រាប់ការអង្កេតអភិបាលកិច្ចនេះ ដោយមានការសម្របសម្រួលពីលេខាធិការដ្ឋាន គ.ជ.អ.ប. ការពិនិត្យពិភាក្សាជាមួយក្រុមការងារបច្ចេកទេសពិគ្រោះយោបល់នៃគម្រោង "**ការពង្រឹងតម្លាភាព និងគណនេយ្យភាពក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ**"

## ៥. កិច្ចការសំខាន់ៗដែលត្រូវរៀបចំ និងអនុវត្ត

ទំហំការងារ និងការទទួលខុសត្រូវរួមរបស់ក្រុមហ៊ុនផ្តល់សេវាទីប្រឹក្សា ឬស្ថាប័នសិក្សាស្រាវជ្រាវ បានកំណត់ក្នុងចំណុច៣ខាងលើ។ ខាងក្រោមនេះគឺជាកិច្ចការចាំបាច់នានាដែលក្រុមហ៊ុនផ្តល់សេវាទីប្រឹក្សា ឬស្ថាប័នសិក្សាស្រាវជ្រាវត្រូវរៀបចំ និងអនុវត្តក្នុងដំណើរការអង្កេតអភិបាលកិច្ចនេះ ក្រោមការសម្របសម្រួលរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.៖

- ការរៀបចំរបាយការណ៍ស្តីពីការចាប់ផ្តើមការធ្វើអង្កេតអភិបាលកិច្ច(inception report) ដែលកំណត់អំពីគោលបំណង ដំណើរការ វិធីសាស្ត្រ ឧបករណ៍ ផែនការសកម្មភាព និងក្របខណ្ឌពេលវេលានៃការអង្កេតអភិបាលកិច្ច
- ការរៀបចំសេចក្តីព្រាងបញ្ជីសំណួរសម្រាប់ប្រមូលព័ត៌មាន និងទិន្នន័យពាក់ព័ន្ធនឹងសូចនាករនៃការផ្តល់សេវាសាធារណៈ ការឆ្លើយតប ការចូលរួមរបស់ប្រជាពលរដ្ឋ តម្លាភាព គណនេយ្យភាពសម្រាប់បង្កើតសន្ទស្សន៍អភិបាលកិច្ច និងសន្ទស្សន៍នៃការផ្តល់សេវា។ ការរៀបចំបញ្ជីសំណួរត្រូវផ្តោតទាំងទៅលើប្រភេទបញ្ជីសំណួរ ទម្រង់ ខ្លឹមសារ និងកំណត់កូដតាមសំណួរសម្រាប់ការវិភាគ ដោយមានការពិគ្រោះយោបល់ និងប្រមូលធាតុចូលពីអ្នកពាក់ព័ន្ធសំខាន់ៗ រួមទាំងអង្គការសង្គមស៊ីវិលដែលធ្វើការពាក់ព័ន្ធនឹងអភិបាលកិច្ចមូលដ្ឋាន និងឬអ្នកជំនាញអភិបាលកិច្ច យេនឌ័រ តម្លាភាព តាមរយៈអនឡាញ និងឬ/ផ្ទាល់។ បញ្ជីសំណួរទាំងនេះចាំបាច់ត្រូវធ្វើតេស្តសាកល្បងទាំងលើការប្រើប្រាស់បញ្ជីសំណួរ ការបញ្ចូលទិន្នន័យ និងការវិភាគទិន្នន័យ។ ការធ្វើតេស្តសាកល្បងនេះត្រូវអនុវត្តនៅក្នុងភូមិចំនួន៤ ឃុំគោលដៅចំនួន២ និងស្រុកគោលដៅចំនួន១
- ពិគ្រោះយោបល់ និងប្រមូលធាតុចូលពីអ្នកពាក់ព័ន្ធសំខាន់ៗ រួមទាំងអង្គការសង្គមស៊ីវិលដែលធ្វើការពាក់ព័ន្ធនឹងអភិបាលកិច្ចមូលដ្ឋាន និងឬអ្នកជំនាញអភិបាលកិច្ច យេនឌ័រ តម្លាភាព តាមរយៈអនឡាញ និង ឬផ្ទាល់/
- ការកំណត់កម្មវិធីកុំព្យូទ័រ (software application) ដែលមានលក្ខណៈសមស្រប និងមានសុវត្ថិភាពខ្ពស់សម្រាប់ផ្ទុកទិន្នន័យ វិភាគទិន្នន័យ និងបង្កើតរបាយការណ៍អំពីសន្ទស្សន៍អភិបាលកិច្ច និងសន្ទស្សន៍ការផ្តល់សេវាសាធារណៈ ដើម្បីធ្វើជាទិន្នន័យដើមគ្រា
- ការជ្រើសរើស និងការបណ្តុះបណ្តាលអ្នកចុះប្រមូលទិន្នន័យ(Enumerators) និងអ្នកត្រួតពិនិត្យការប្រមូលទិន្នន័យ (Supervisors)ដោយត្រូវជ្រើសរើសអ្នកប្រមូលទិន្នន័យដែលមានចំណេះដឹងសមស្រប (យ៉ាងហោចជានិស្សិតដែលកំពុងសិក្សាតាមមហាវិទ្យាល័យ) និងក្នុងចំនួនសមស្រប ព្រមទាំងផ្តល់ការបណ្តុះបណ្តាលអ្នកប្រមូលទិន្នន័យឱ្យមានការយល់ដឹងច្បាស់អំពីបញ្ជីសំណួរ ការប្រើប្រាស់បញ្ជីសំណួរ ការសម្ភាសន៍ប្រមូលព័ត៌មាន ការបញ្ចូល

ទិន្នន័យ ការពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យជាដើម។ បន្ទាប់ពីការបណ្តុះបណ្តាលត្រូវរៀបចំអនុវត្តសាកល្បងក្នុងការចុះប្រមូលទិន្នន័យ ដើម្បីធានាឱ្យអ្នកប្រមូលទិន្នន័យយល់ដឹងច្បាស់ និងមានការជឿជាក់ក្នុងការចុះប្រមូលទិន្នន័យបានយ៉ាងត្រឹមត្រូវ

- ការកំណត់វិធីសាស្ត្រជ្រើសរើសសំណាក រួមទាំងការកំណត់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិគោលដៅ និងការជ្រើសរើសអ្នកផ្តល់ព័ត៌មាន (ប្រជាជន សមាជិកក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីផ្តល់សេវា)
- ការចុះប្រមូលព័ត៌មាននៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិគោលដៅ ដោយអនុវត្តតាមវិធីសាស្ត្រដែលបានកំណត់។ ការចុះប្រមូលទិន្នន័យនៅតាមមូលដ្ឋានត្រូវរៀបចំឱ្យមានយន្តការគ្រប់គ្រង តាមដាន ត្រួតពិនិត្យលើការបំពេញការងាររបស់អ្នកចុះប្រមូលព័ត៌មានជាប្រចាំដើម្បីធានាដល់ការប្រមូលបាននូវទិន្នន័យទាន់ពេលវេលាដែលបានកំណត់ និងមានភាពត្រឹមត្រូវក្នុងកម្រិតអតិបរមានៃទិន្នន័យដែលប្រមូលបាន
- ការបញ្ចូលទិន្នន័យដែលប្រមូលបានទៅក្នុងកម្មវិធីកុំព្យូទ័រដែលបានកំណត់ ដោយមានយន្តការពិនិត្យ ផ្ទៀងផ្ទាត់ដើម្បីធានានូវភាពត្រឹមត្រូវនៃការបញ្ចូលទិន្នន័យស្របតាមនីតិវិធី និងលេខកូដដែលបានកំណត់ ព្រមទាំងត្រូវធានានូវសុវត្ថិភាពទិន្នន័យទាំងអស់ផងដែរ
- ការវិភាគទិន្នន័យដោយប្រើប្រាស់កម្មវិធីកុំព្យូទ័រដែល software program/application ដែលបានកំណត់ ដើម្បីរៀបចំបង្កើតសន្ទស្សន៍អភិបាលកិច្ច និងសន្ទស្សន៍នៃការផ្តល់សេវាសាធារណៈនៃការអង្កេតអភិបាលកិច្ចដែលជាទិន្នន័យដើមគ្រាសម្រាប់ជាមូលដ្ឋានក្នុងការវាស់វែងកម្រិតនៃការសម្រេចបាននូវគោលដៅ និងគោលបំណងនៃ**កជទី២**
- ការរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើលទ្ធផលបឋមនៃការអង្កេតអភិបាលកិច្ច ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធសំខាន់ៗ រួមទាំងអង្គការសង្គមស៊ីវិលដែលធ្វើការពាក់ព័ន្ធនឹងអភិបាលកិច្ចមូលដ្ឋាន និងអ្នកជំនាញយេនឌ័រ
- ការរៀបចំរបាយការណ៍ស្តីពីដំណើរការ និងលទ្ធផលនៃការអង្កេតអភិបាលកិច្ច។

ក្រុមហ៊ុនផ្តល់សេវាទីប្រឹក្សា ឬស្ថាប័នសិក្សាស្រាវជ្រាវត្រូវរៀបចំ និងអនុវត្តសកម្មភាពចាំបាច់ទាំងនេះ ដោយមានការសម្របសម្រួលពីលេខាធិការដ្ឋាន គ.ជ.អ.ប. ការពិនិត្យ ពិភាក្សាជាមួយក្រុមការងារបច្ចេកទេសពិគ្រោះយោបល់នៃគម្រោង "**ការពង្រឹងតម្លាភាព និងគណនេយ្យភាពក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ**" និងការឯកភាពពីលេខាធិការដ្ឋាន គ.ជ.អ.ប។

## ៦. លទ្ធផលសំខាន់ៗដែលត្រូវសម្រេចបាន (Deliverable)

ក្រុមហ៊ុនផ្តល់សេវាទីប្រឹក្សា ឬស្ថាប័នសិក្សាស្រាវជ្រាវត្រូវរៀបចំដែលត្រូវបានជ្រើសរើស និងចុះកិច្ចសន្យាការងារជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវធានាសម្រេចឱ្យបាននូវលទ្ធផលសំខាន់ៗដូចខាងក្រោម៖

១. របាយការណ៍ស្តីពីការចាប់ផ្តើមការធ្វើអង្កេតអភិបាលកិច្ច (inception report) បន្ទាប់ពីការចុះកិច្ចសន្យារយៈ ២០ថ្ងៃ (ជាភាសាខ្មែរ និងអង់គ្លេស)ដែលបរិយាយអំពីវិធីសាស្ត្រ និងកម្មវិធីគ្រោងពេលការងារ

២. រៀបចំសេចក្តីព្រាងបញ្ជីសំណួរដែលត្រូវប្រើប្រាស់សម្រាប់ប្រមូលទិន្នន័យដើម្បីរៀបចំសន្ទស្សន៍អភិបាលកិច្ច និងសន្ទស្សន៍នៃការផ្តល់សេវាសាធារណៈ (ជាភាសាខ្មែរ និងអង់គ្លេស)

៣. ទិន្នន័យដែលបានបញ្ចូលក្នុងកម្មវិធីកុំព្យូទ័រដែលបានកំណត់ ដើម្បីបង្កើតជាសន្ទស្សន៍អភិបាលកិច្ចនិងសន្ទស្សន៍ការផ្តល់សេវាសាធារណៈដែលលទ្ធផលនៃការអង្កេតអភិបាលកិច្ច (ទិន្នន័យដើមគ្រា)

៤. សិក្ខាសាលាពិគ្រោះយោបល់ទៅលើលទ្ធផលនៃការអង្កេតអភិបាលកិច្ច ដែលមានអ្នកចូលរួមជាក្រុមការងារពិគ្រោះយោបល់ និងអ្នកពាក់ព័ន្ធនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (បទបង្ហាញ និងរបាយការណ៍សិក្ខាសាលាជាភាសាខ្មែរ និងអង់គ្លេស)

៥. របាយការណ៍វឌ្ឍនភាពបឋមស្តីពីលទ្ធផលនៃការអង្កេតអភិបាលកិច្ច ដែលរៀបរាប់អំពីវិធីសាស្ត្រ កិច្ចដំណើរការ របៀបនៃការបង្កើត និងការបកស្រាយពន្យល់អំពីសន្ទស្សន៍អភិបាលកិច្ច និងសន្ទស្សន៍នៃការផ្តល់សេវាសាធារណៈដែលជាលទ្ធផលនៃការអង្កេតអភិបាលកិច្ចដែលជាទិន្នន័យដើមគ្រា និងបញ្ហាប្រឈមនានានៃការធ្វើអង្កេតអភិបាលកិច្ចនេះ។ របាយការណ៍នេះត្រូវជាភាសាខ្មែរ និងភាសាអង់គ្លេស។

## ៧. លក្ខខណ្ឌជ្រើសរើសក្រុមហ៊ុនផ្តល់សេវាទីប្រឹក្សា ឬស្ថាប័នសិក្សាស្រាវជ្រាវ

ក្រុមហ៊ុនផ្តល់សេវាទីប្រឹក្សា ឬស្ថាប័នសិក្សាស្រាវជ្រាវដែលមានបំណងផ្តល់សេវាអង្កេតអភិបាលកិច្ចនេះ ត្រូវមានក្រុមទីប្រឹក្សាជំនាញយ៉ាងតិច៣រូបក្នុងនោះរួមមាន៖

**១. ប្រធានក្រុមទីប្រឹក្សា** (Team leader) ដែលមានការសិក្សាយ៉ាងទាបកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ (Master Degree) ផ្នែកច្បាប់ ឬផ្នែកគោលនយោបាយសាធារណៈ ឬផ្នែកគ្រប់គ្រងរដ្ឋបាលសាធារណៈ ឬផ្នែកសេដ្ឋកិច្ច និងមានបទពិសោធន៍ការងារពាក់ព័ន្ធនឹងការងារអភិបាលកិច្ច ការងារផែនការ ការត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងធ្លាប់ដឹកនាំគ្រប់គ្រងការធ្វើអង្កេតផ្នែកអភិបាលកិច្ច និងអង្កេតផ្នែកគោលនយោបាយក្នុងទ្រង់ទ្រាយធំ។

**២. អនុប្រធានក្រុមទីប្រឹក្សា** (Deputy Team Leader) ដែលមានការសិក្សាយ៉ាងទាបកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ (Master Degree) ផ្នែកគោលនយោបាយរដ្ឋបាលសាធារណៈ ឬផ្នែកសេដ្ឋកិច្ច និងមានបទពិសោធន៍ការងារពាក់ព័ន្ធនឹងការរៀបចំ ការគ្រប់គ្រង និងការប្រើប្រាស់ប្រព័ន្ធ ឬកម្មវិធីកុំព្យូទ័រពាក់ព័ន្ធនឹងទិន្នន័យមូលដ្ឋាន (database software program/application) ការវិភាគទិន្នន័យ ព្រមទាំងធ្លាប់ចូលរួមដឹកនាំគ្រប់គ្រងការធ្វើអង្កេតផ្នែកអភិបាលកិច្ច និងផ្នែកគោលនយោបាយក្នុងទ្រង់ទ្រាយធំ និងមានតួនាទីរៀបចំប្លង់អង្កេត សំណាក និងឧបករណ៍ប្រមូលទិន្នន័យ។

**៣.ទីប្រឹក្សាជំនាញផ្នែកស្ថិតិ** (statistic specialist) ដែលមានការសិក្សាយ៉ាងទាបកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ (Master Degree) ផ្នែកស្ថិតិ ផ្នែកបច្ចេកវិទ្យាព័ត៌មានវិទ្យា (IT) ឬផ្នែកគោល

នយោបាយសាធារណៈ ឬផ្នែកសេដ្ឋកិច្ច និងមានបទពិសោធន៍ការងារពាក់ព័ន្ធនឹងការរៀបចំ និងការប្រមូលទិន្នន័យ ការបញ្ចូលទិន្នន័យ ការវិភាគទិន្នន័យ ព្រមទាំងធ្លាប់ចូលរួមការធ្វើអង្កេតផ្នែកអភិបាលកិច្ច និងផ្នែកគោលនយោបាយក្នុងទ្រង់ទ្រាយធំ។

**៤. ទីប្រឹក្សាជំនាញផ្នែកមូលដ្ឋានទិន្នន័យ** (database specialist) ត្រូវមានកំរិតវប្បធម៌បរិញ្ញាបត្រផ្នែកព័ត៌មានវិទ្យា និងធ្លាប់បំពេញការងារជាអ្នកជំនាញទិន្នន័យ និងធ្លាប់មានបទពិសោធន៍ប្រើប្រាស់កម្មវិធី SPSS, STRATA។

ក្រៅពីក្រុមទីប្រឹក្សាជំនាញខាងលើ ក្រុមហ៊ុនផ្តល់សេវាទីប្រឹក្សា ឬស្ថាប័នសិក្សាស្រាវជ្រាវត្រូវមានលទ្ធភាពក្នុងជ្រើសរើសអ្នកប្រមូលទិន្នន័យ (enumerator) យ៉ាងតិច២៥រូប និងអ្នកត្រួតពិនិត្យការប្រមូលទិន្នន័យ (supervisor) យ៉ាងតិច៥រូប ដែលមានលក្ខណៈសម្បត្តិល្អគ្រប់គ្រាន់ និងជានិស្សិតកំពុងសិក្សានៅតាមសកលវិទ្យាល័យ ឬនិស្សិតដែលបានបញ្ចប់ការសក្សាមានបរិញ្ញាបត្រផ្នែកសង្គមវិទ្យា ផ្នែកវិទ្យាសាស្ត្រ មានកាយសម្បទា និងសុខភាពល្អ។ ក្រុមហ៊ុនផ្តល់សេវាទីប្រឹក្សា ឬស្ថាប័នសិក្សាស្រាវជ្រាវត្រូវមានផ្តល់ការបណ្តុះបណ្តាលដល់អ្នកប្រមូលព័ត៌មានអំពីជំនាញសម្ភាសន៍ ជំនាញប្រមូលទិន្នន័យ និងការប្រើប្រាស់ឧបករណ៍ សម្ភារចាំបាច់នានាពាក់ព័ន្ធនានាក្នុងការចុះប្រមូលទិន្នន័យនៅតាមមូលដ្ឋានឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។

រយៈពេលនៃការបំពេញការងាររបស់ក្រុមទីប្រឹក្សាប្រឹក្សាជំនាញ អ្នកប្រមូលព័ត៌មាន និងអ្នកត្រួតពិនិត្យសម្រាប់ការធ្វើអង្កេតអភិបាលកិច្ចនេះ ត្រូវប៉ាន់ស្មានដូចខាងក្រោម៖

| **ល.រ** | **មុខតំណែង** | **ចំនួនថ្ងៃបំពេញការងារ** |
|---|---|---|
| ១ | ប្រធានក្រុមទីប្រឹក្សា (Team leader) | ៦០ នាក់/ថ្ងៃ |
| ២ | អនុប្រធានក្រុមទីប្រឹក្សា (Deputy Team Leader) | ១០០ នាក់/ថ្ងៃ |
| ៣ | ទីប្រឹក្សាជំនាញផ្នែកស្ថិតិ (statistic specialist) | ១០០ នាក់/ថ្ងៃ |
| ៤ | ទីប្រឹក្សាជំនាញផ្នែកមូលដ្ឋានទិន្នន័យ (database specialist) | ១០០ នាក់/ថ្ងៃ |
| ៥ | អ្នកប្រមូលទិន្នន័យនិងអ្នកត្រួតពិនិត្យ(enumeratorនិងsupervisor) | ៨០០ នាក់/ថ្ងៃ |

## ៨. ព័ត៌មានសំខាន់ៗសម្រាប់ការដាក់ពាក្យ

ក្រុមហ៊ុនផ្តល់សេវាទីប្រឹក្សា ឬស្ថាប័នសិក្សាស្រាវជ្រាវដែលមានបំណងធ្វើការអង្កេតអភិបាលកិច្ចនេះត្រូវដាក់ពាក្យស្នើសុំដោយត្រូវមានព័ត៌មានសំខាន់ៗដូចខាងក្រោម៖

- ជាក្រុមហ៊ុនផ្តល់សេវាទីប្រឹក្សា ឬស្ថាប័នសិក្សាស្រាវជ្រាវដែលមានការចុះបញ្ជីត្រឹមត្រូវ
- ព័ត៌មានលំអិតអំពីបទពិសោធន៍ក្នុងការធ្វើការស្ទង់មតិខ្នាតធំ
- ហេតុផលសំខាន់ៗសម្រាប់ការដាក់សំណើនេះ
- ផែនការការងារសម្រាប់ការធ្វើអង្កេតនេះ

- បង្ហាញអំពីបច្ចេកទេសក្នុងការគ្រប់គ្រងការចុះប្រមូលទិន្នន័យដែលធានានូវគុណភាព និង ភាពត្រឹមត្រូវនៃទិន្នន័យ (ចំនួនអ្នកប្រមូលទិន្នន័យ របៀបនៃការចាត់ចែង និងគ្រប់គ្រងការប្រមូល ការបញ្ចូលទិន្នន័យ)
- គម្រោងថវិកាដែលស្នើឡើងដែលមានចំនួនសមស្រប និងសមហេតុផល
- បញ្ជីឈ្មោះបុគ្គលិកសំខាន់ៗ តួនាទីបុគ្គលិកទាំងនោះក្នុងការធ្វើអង្កេតអភិបាលកិច្ច រួមជាមួយនឹងច្បាប់ចម្លងនៃប្រវត្តិរូបសង្ខេបរបស់បុគ្គលិកទាំងនោះផងដែរ
- ឯកសារយោងចំនួនបី ដែលបញ្ជាក់ពីបទពិសោធន៍ដែលធ្លាប់បានធ្វើនាពេលកន្លងមក។

លេខាធិការដ្ឋាន គ.ជ.អ.ប. នឹងវាយតម្លៃសំណើរបស់ក្រុមហ៊ុនផ្តល់សេវាទីប្រឹក្សា ឬស្ថាប័នសិក្សាស្រាវជ្រាវដោយផ្អែកលើ៖

- ប្រវត្តិ គោលបំណង និងការបង្កើតក្រុមហ៊ុនផ្តល់សេវាទីប្រឹក្សា ឬស្ថាប័នសិក្សាស្រាវជ្រាវ
- បទពិសោធន៍របស់ប្រធានក្រុមទីប្រឹក្សា អនុប្រធានក្រុមទីប្រឹក្សា និងទីប្រឹក្សាជំនាញពាក់ព័ន្ធសំខាន់ៗដែលបានស្នើឡើងសម្រាប់ការធ្វើអង្កេតអភិបាលកិច្ចនេះ។
- កំណត់ត្រាល្អៗនៃការប្រមូលទិន្នន័យ និងកេរ្តិ៍ឈ្មោះក្នុងការផ្តល់នូវគុណភាពល្អនៃទិន្នន័យ។
- បច្ចេកទេសគ្រប់គ្រងការប្រមូល ការបញ្ចូល និងការវិភាគទិន្នន័យ។

## ៩. ការប្រើប្រាស់ទិន្នន័យ និងក្របខណ្ឌពេលវេលា

របាយការណ៍លទ្ធផលនៃការធ្វើអង្កេតអភិបាលកិច្ចនេះ គឺជាទ្រព្យសម្បត្តិផ្តាច់មុខរបស់លេខាធិការដ្ឋានគ.ជ.អ.ប. និងត្រូវអនុវត្តឱ្យបានចប់សព្វគ្រប់យ៉ាងយូរក្នុងរយៈពេល**៥ខែ**បន្ទាប់ពីពេលចុះកិច្ចសន្យាការងារជាមួយ លេខាធិការដ្ឋាន គ.ជ.អ.ប.។